អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧

# សេចក្តីថ្លែងការណ៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាតិស្តីពីសំណុំរឿង០០៣

នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ក្នុងសំណុំរឿង០០៣ ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរលើ មាស មុត។ វិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា ខណៈដែលដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាត្រូវបានដាក់ជាការសម្ងាត់ក៏ដោយ ក៏សហព្រះរាជអាជ្ញា អាចបញ្ចេញនូវសេចក្តីសង្ខេបអំពីគោលបំណងនៃសេចក្តីសន្និដ្ឋានរបស់ខ្លួន ជូនសាធារណជនបានដែរ។ ដើម្បីតម្លាភាពជាប្រយោជន៍ដល់សាធារណៈ សហព្រះរាជអាជ្ញាសូមផ្តល់ជូននូវសេចក្តីសង្ខេបព័ត៌មានដូចខាងក្រោម ដែលមាននៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ទាក់ទងនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿង មាស មុត។ សូមអ្នកអានជ្រាបថា សេចក្តីសង្ខេបខាងក្រោមនេះ មិនរាប់បញ្ចូលទស្សនៈរបស់មេធាវីការពារក្តី ហើយក៏មិនមែនមានចេតនាឆ្លុះបញ្ចាំងអំពីទស្សនៈរបស់សហចៅក្រមស៊ើបអង្កេត(“សចស”)ដែរ ដោយសារពួកគាត់នឹងធ្វើការកំណត់លើបញ្ហាទាំងអស់នេះដោយពួកគាត់ផ្ទាល់។

ដីកាសន្និដ្ឋានស្ថាពរត្រូវបានចេញដោយសហព្រះរាជអាជ្ញានៅពេលបិទកិច្ចស៊ើបសួរ។ ក្នុងដីកាសន្និដ្ឋានស្ថាពរ សហព្រះរាជអាជ្ញាអាចស្នើឲ្យ សចស បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់នៅក្នុងសំណុំរឿងនោះ។

សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពរដាច់ដោយឡែកពីគ្នាដែលឆ្លុះបញ្ចាំងពីទស្សនៈខុសគ្នាអំពីថាតើ គួរស្នើសុំឲ្យ សចស ចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬលើកលែងចោទប្រកាន់។ មេធាវីការពារក្តី មាស មុត ឥឡូវនេះនឹងមានឱកាសឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរទាំងនេះជាមួយនឹងទស្សនៈរបស់ខ្លួនអំពីច្បាប់ និងភ័ស្តុតាង។ បន្ទាប់មក វាអាស្រ័យលើសហចៅក្រមស៊ើបអង្កេតដែលនឹងត្រូវសម្រេចថា

តើ មាស មុត ត្រូវដាក់ឲ្យស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា និងថាតើការស៊ើបអង្កេតនេះបានបង្ហាញឲ្យឃើញអំពីការទទួលខុសត្រូវរបស់គាត់ ចំពោះឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដល់បទដ្ឋានដែលតម្រូវដើម្បីចោទប្រកាន់គាត់ និងបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ ឬយ៉ាងណា។ ដូចគ្នាទៅនឹងជនត្រូវចោទ និងជនជាប់ចោទទាំងអស់នៅ អ.វ.ត.ក ដែរ មាស មុត នៅតែរក្សាការសន្មតថាគ្មានទោសដដែលរហូតមកដល់ពេលនេះ ដរាបណា ឬនៅពេលណាដែលពិរុទ្ធភាពរបស់គាត់ត្រូវបានរកឃើញនៅពេលសវនាការ និងត្រូវបានតម្កល់តាមរយៈបណ្តឹងសាទុក្ខណាមួយ។

សហព្រះរាជអាជ្ញាជាតិមានជំហរតាំងពីដើមរៀងរហូតមកថា គឺមានតែជនជាប់ចោទដែលមានស្រាប់នៅ អវតក ដែលជាមេដឹកនាំជាន់ខ្ពស់ និងជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ ដែលស្ថិតក្នុងយុត្តាធិការបុគ្គលនៃ អវតក ។ តាមរយៈការយល់ឃើញនេះ ទើបសហព្រះរាជអាជ្ញាជាតិ មិនត្រឹមតែមិនចូលរួមក្នុងកិច្ចនីតិវិធីស៊ើបអង្កេតបឋមរបស់ការិយាល័យសហព្រះរាជអាជ្ញា និងកិច្ចនីតិវិធីស៊ើបអង្កេតរបស់ការិយាល័យចៅក្រមស៊ើបសួរប៉ុណ្ណោះទេ ថែមទាំងលើកការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ស្របតាមវិធានផ្ទៃក្នុងនៃ អវតក នៅគ្រប់ដំណាក់កាល។

សហព្រះរាជអាជ្ញាជាតិកត់សម្គាល់ឃើញថា អ.វ.ត.ក គួរតែផ្តល់អាទិភាពទៅលើការវិនិច្ឆ័យទោសជនជាប់ចោទទាំងនេះ ដើម្បីបំពេញឲ្យបានគ្រប់គ្រាន់ចំពោះអាណត្តិរបស់ខ្លួន ព្រោះថា ច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានគិតទុកជាមុនរួចហើយ អំពីការវិនិច្ឆ័យទោសដែលត្រូវធ្វើតែទៅលើបុគ្គលមួយចំនួនតូចប៉ុណ្ណោះ។

សហព្រះរាជអាជ្ញាជាតិពិនិត្យឃើញថា តាមរយៈបុព្វកថានៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាដែលបានអនុមតក្នុងសេចក្តីសម្រេចចិត្តលេខ៖៥៧/២២៨ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ អង្គការសហប្រជាជាតិបានទទួលស្គាល់យ៉ាងជាក់លាក់អំពីការព្រួយបារម្ភពេញច្បាប់របស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខ។ ផ្តើមចេញពីការទទួលស្គាល់នេះ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានតម្រូវឲ្យសហព្រះរាជអាជ្ញា ជ្រើសរើស

យកបុគ្គលតែពីរប្រភេទប៉ុណ្ណោះមកធ្វើការវិនិច្ឆ័យសេចក្តី គឺមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

សហព្រះរាជអាជ្ញាជាតិយល់ឃើញថា វានឹងមិនបម្រើផលប្រយោជន៍នៃយុត្តិធម៌ទេ ក្នុងការបញ្ជូនបុគ្គល មាស មុត ទៅជំនុំជម្រះ ប្រសិនបើការចោទប្រកាន់ទៅលើរូបគាត់នោះ នឹងបង្អាក់ដល់នយោបាយក្នុងស្រុក និងបណ្តាលឲ្យមានចលាចលជាសក្តានុពលយ៉ាងធ្ងន់ធ្ងរនោះ។

ហេតុដូច្នេះ សហព្រះរាជអាជ្ញាជាតិប្រកាន់ជំហរថា យោងតាមបទប្បញ្ញត្តិនៃច្បាប់បង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាដែលបានបង្កើតតុលាការនេះ គឺ មាស មុត ដែលមានឈ្មោះនៅក្នុងសំណុំរឿងលេខ០០៣ មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ។

សូមរំលឹកចំពោះសាធារណជនថា គ្រប់ជនសង្ស័យ និងជនត្រូវចោទ ឬបុគ្គលដែលបានបញ្ជូនទៅជំនុំជម្រះទាំងអស់ គឺត្រូវបានសន្មតថាគ្មានទោស លើកលែងតែ និងរហូតទាល់តែពិរុទ្ធភាពរបស់ពួកគាត់ត្រូវបានបង្ហាញសក្ខីកម្មឲ្យហួសពីវិមតិសង្ស័យនៅក្នុងតុលាការ និងត្រូវបានតម្កល់ដោយបណ្តឹងឧទ្ធរណ៍ណាមួយ។ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ អនុលោមតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


**លោកស្រី ហាយ៉ាត់ អាប៊ូ-សាឡេស**
មន្ត្រីព័ត៌មានសាធារណៈ

ទូរស័ព្ទចល័តៈ +៨៥៥ (០)១២ ៤៨៨ ៩៣៦

សារអេឡិចត្រូនិកៈ abusaleh@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម

ទូរស័ព្ទចល័តៈ +៨៥៥ (០)១២ ៤៨៨ ១៥៦

សារអេឡិចត្រូនិកៈ neth.phektra@eccc.gov.kh